# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Mar-2011, 13:46
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់ អៀង សារី សុំបញ្ជាក់ថា តើសេចក្ដីសម្រេច និង ដីកាបង្គាប់នានាត្រូវបាន ធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងទាំងមូលដែរ ឬអត់

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្ដម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមស្នើឲ្យបញ្ជាក់ថា តើសេចក្តីសម្រេច និងដីកាបង្គាប់ទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើងអង្គចៅក្រមទាំងមូលដែរ ឬអត់ ដូចដែលតម្រូវដោយកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ។ ញត្តិនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះមានការលេចឮថាសេចក្តីសម្រេច និងដីកាបង្គាប់ទាំងអស់របស់អង្គជំនុំជម្រះនៅក្នុងករណី ០០២ ត្រូវបានចេញក្នុងនាមប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន តែម្នាក់គត់។ វាមានលក្ខណៈមិនច្បាស់លាស់ថា តើចៅក្រម និល ណុន កំពុងតែចេញដីកាបង្គាប់ និងសេចក្តីសម្រេចទាំងអស់នេះតាងនាមឲ្យអង្គជំនុំជម្រះទាំងមូល បន្ទាប់ពីបានពិភាក្សាយ៉ាងពេញលេញដោយចៅក្រមទាំងស់របស់អង្គជំនុំជម្រះសាលាដំបូងដែរ ឬយ៉ាងណា ។

## I ច្បាប់ដែលយកមកអនុវត្ត

១. មាត្រា ៤ នៃកិច្ចព្រមព្រៀងចែងថា:

១. ចៅក្រមត្រូវព្យាយាមឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទ នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន ប្រសិនបើមិនអាចទទួលបានការឯកភាពជាឯកច្ឆ័ន្ទទេ ត្រូវអនុវត្តវិធានបមន្តខាងក្រោម:

ក- ការសម្រេចសេចក្តីរបស់សាលាដំបូងតម្រូវឲ្យមានសំឡេងគាំទ្រពីចៅក្រមបួននាក់យ៉ាងតិច...

២. នៅពេលដែលគ្មានការឯកភាពច្ឆ័ន្ទទេ ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះត្រូវមានទស្សនៈរបស់មតិភាគច្រើន និងមតិភាគតិច ។

២. មាត្រា ១៤ ថ្មីនៃច្បាប់បង្កើត អវតក ចែងថា:

១. ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឲ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន ប្រសិនបើភាពឯកច្ឆ័ន្ទនេះមិនអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ខាងក្រោម:

ក- ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួននាក់យ៉ាងតិច...

២. នៅពេលដែលពុំមានឯកភាពឯកច្ឆ័ន្ទទេ ការសម្រេចសេចក្តីនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់មតិភាគច្រើន និងមតិភាគតិច ។

## II. អំណះអំណាង

៣. កិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ចែងយ៉ាងច្បាស់ថា ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួននាក់យ៉ាងតិច ។ ប៉ុន្តែ សេចក្ដីសម្រេចភាគច្រើននៅក្នុងករណី ០០២ ត្រូវបានចុះហត្ថលេខាដោយចៅក្រម និល ណុន តែម្នាក់ប៉ុណ្ណោះ[1]។ ជួនកាលសេចក្ដីសម្រេចត្រូវបានចេញនៅក្នុងទម្រង់ជាអនុស្សរណៈដែលបញ្ជាក់ថា អនុស្សរណៈពីចៅក្រម និល ណុន[2] ឬ ពីមន្ត្រីច្បាប់ជាន់ខ្ពស់ Susan Lamb[3]។ អាស្រ័យហេតុនេះ វាមានលក្ខណៈមិនច្បាស់លាស់ថា តើចៅក្រមទាំងអស់ត្រូវបានជូនដំណឹង និងបានចូលរួមពិភាក្សាយ៉ាងពេញលេញ និងបោះឆ្នោតគាំទ្រសេចក្ដីសម្រេច ដែលត្រូវបានចុះហត្ថលេខាដោយចៅក្រម និល ណុន តែម្នាក់ឯងនោះដែរឬអត់ ។ ប្រសិនបើការសម្រេចសេចក្ដីមិនត្រូវបានធ្វើឡើងក្នុងនាមអង្គជំនុំជម្រះទាំងមូលទេ នោះសេចក្ដីសម្រេចទាំងអស់នេះមិនមានសុពលភាពទេ ។

៤. ថ្វីត្បិតតែកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក មិនបានចែងថា តើដីកាបង្គាប់ត្រូវតែបានបោះឆ្នោតគាំទ្រ និងតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រមបួននាក់យ៉ាងតិចនៃអង្គជំនុំជម្រះសាលាដំបូងក៏មិនមូលហេតុណាដែលថាដីកាបង្គាប់ត្រូវបានចាត់ទុកថាខុសគ្នាពីសេចក្ដីសម្រេចដែរ ។ វាហាក់ដូចជាថាដីកាបង្គាប់ទាំងអស់នៅក្នុងករណី ០០២ ពុំបានចុះហត្ថលេខាដោយចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូងឡើយ ។ ជំនួសមកវិញ ចៅក្រម និល ណុន ចុះហត្ថលេខាលើដីកាបង្គាប់

---

[1] សូមមើល ឧទាហរណ៍*ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អជសដ, សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ E9/16/4, ERN: 006457167-00657169 ។

[2] សូមមើល ឧទាហរណ៍*ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អជសដ, សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលវេលាកំណត់ (E9/7/ និង E9/4/9) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ E9/7/1, ERN: 00648637-00648637 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អជសដ, អនុស្សរណៈស្ដីពីសេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់ញត្តិសុំឱ្យមាន "ការបញ្ជាក់ថាគាត់ត្រូវបានអនុញ្ញាតិឱ្យបង្ហាញទឡ្ហីករណ៍ផ្ទាល់នៅសវនាការបឋមអំពីអញ្ញត្រកម្មនីមួយៗរបស់គាត់" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១, E65/1, ERN: 00651599-00651600 ។

[3] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អជសដ, អនុស្សរណៈអន្តរការិយាល័យពី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅភាគីទាំងអស់នៅក្នុងករណី ០០២ ស្ដីពីការជូនដំណឹងជាមុននៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិ៖ E14, E15, E9/2, E9/3, E/24 និង E27 ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ E35, ERN: 00642291-00642292 ។ *ករណី នួន ជា* ០០២/១៩-០៩-២០០៧/អជសដ, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ: នីតិវិធីបណ្ដោះអាសន្ននៅចំពោះអង្គជំនុំជម្រះសាលាដំបូង នៅក្នុងករណីមានភាពជាប់គាំងខាងបកប្រែធ្វើឱ្យភាគីមិនអាចដាក់ឯកសារតាមពេលវេលាកំណត់ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ E35, ERN: 00642291-00642292 ។

ទាំងអស់នេះតែម្នាក់ឯងប៉ុណ្ណោះ[4] ។ មេធាវីការពារសូមស្នើដោយគោរពឲ្យបញ្ជាក់ថា តើអង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ដីកាបង្គាប់នានាអាចចេញដោយចៅក្រមតែម្នាក់ដែរឬទេ ហើយសុំការបញ្ជាក់ថា តើដីកាបង្គាប់នានាដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើងតាងនាមឲ្យអង្គជំនុំជម្រះទាំងមូលដែរ ឬអត់ ។

## III សំណូមពរ

អាស្រ័យដោយហេតុផលទាំងអស់ដែលបានបញ្ជាក់នៅក្នុងសំណើនេះ មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាបញ្ជាក់ថាតើ:

ក. សេចក្តីសម្រេចទាំងអស់ត្រូវបានធ្វើឡើងតាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូងទាំងមូលដែរ ឬអត់ ។

ខ. ដីកាបង្គាប់ទាំងឡាយអាចត្រូវបានចុះហត្ថលេខាដោយចៅក្រមតែម្នាក់ដែរ ឬអត់ និង

គ. ដីកាបង្គាប់ទាំងអស់ត្រូវធ្វើឡើងតាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូងទាំងមូលដែរ ឬអត់ ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៣១** ខែ **មីនា** ឆ្នាំ **២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[4] *ករណី នួន ជា* ០០២/១៩-០៩-២០០៧/អជសដ, ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីត្រៀមរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១១ E9, ERN: 00635754-00635759 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អជសដ, ដីកាបង្គាប់ឲ្យមេធាវីការពារ អៀង សារី ដាក់អញ្ញត្រកម្ម ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១១ E51/6, ERN: 00648420-00648421 ។